# របៀបធ្វើការទូទាត់សាច់ប្រាក់ទៅឲ្យក្រុមហ៊ុន ឌីធីវីស្ការ (ឌីជី)

## ១-តាមរយៈបណ្ដាញម៉ាស៊ីន អេធីអឹម របស់ធនាគារ ABA

- បញ្ចូលកាតទៅក្នុងម៉ាស៊ីន អេធីអឹម
- ធ្វើការជ្រើសរើសភាសា **ខេមរភាសា**
- បញ្ចូលលេខកូដសំងាត់
- ជ្រើសរើសយក **សេវាផ្សេងៗ**
- ជ្រើសរើសយក **សេវាទូទាត់**
- ជ្រើសរើសយក **ឌីធីវីស្ការ(ឌីជី)**
- បញ្ចូលលេខ សំគាល់អតិថិជនរបស់អ៊ីនធើណិតឌីជី (សូមមើលពីរបៀបរកមើលលេខអតិថិជនរបស់លោកអ្នក) ហើយចុច **យល់ព្រម**
- បញ្ចូលចំនួនទឹកប្រាក់ដែលត្រូវបង់ (សូមមើលរបៀបរកមើលចំនួនទឹកប្រាក់ដែលត្រូវបង់ពីវិក័យប័ត្របង់ប្រាក់ឌីជី) ហើយចុច **យល់ព្រម**
- ចុចយក **ត្រូវការ** បើសិនជាចង់បានសន្លឹកវិក័យប័ត្របន្ទាប់ពីប្រតិបត្តិការដំណើរការរួចរាល់ ឬក៏ចុច **មិនត្រូវការ** បើមិនចង់បានសន្លឹកវិក័យប័ត្រ
- ធ្វើការផ្ទៀងផ្ទាត់ការទូទាត់របស់លោកអ្នក។ បើពុំមានកំហុសទេសូមចុច **ត្រឹមត្រូវ**។ បើសិនមានកំហុសសូមចុច **មិនត្រឹមត្រូវទេ** ដើម្បីបដិសេធកាទូទាត់។
- សូមរង់ចាំឲ្យវាដំណើររួចរាល់។ បើចង់បន្តធ្វើប្រតិបត្តិការផ្សេងទៀតសូមចុច យល់ព្រម បើមិនចង់ធ្វើទេចុចពាក្យ មិនត្រូវការទេ។

  - ការបង្ហាញពីការអនុវត្តនៃការទូទាត់វិក័យប័ត្ររបស់ឌីជីនៅក្នុងម៉ាស៊ីន អេធីអឹម៖







សូមវាយបញ្ចូលលេខសំងាត់ ៤ខ្ទង់
របស់លោកអ្នក
សូមចុច CANCEL ដើម្បីចាកចេញ


សូមធ្វើការជ្រើសរើសប្រភេទ
ប្រតិបត្តិការខាងក្រោម
ផ្ទេរប្រាក់រវាងគណនី
ដកប្រាក់រហ័ស
របាយការណ៍សង្ខេប
ដកប្រាក់
ទិញកាតទូរស័ព្ទ
ប្តូរលេខសំងាត់
សេវាផ្សេងៗ
សមតុល្យសាច់ប្រាក់


សូមធ្វើការជ្រើសរើស
ប្រតិបត្តិការខាងក្រោម
ផ្ទេរប្រាក់រវាងប័ណ្ណ
សេវាទូទាត់
ត្រឡប់ក្រោយ


សូមធ្វើការជ្រើសរើស
អ្នកផ្គត់ផ្គង់សេវាកម្ម
អគ្គិសនីកម្ពុជា
ឌីធីវីស្ទារ(ឌីធី)
អ៊ីហ្សីខម
ត្រឡប់ក្រោយ


សូមបញ្ចូល លេខសំគាល់អតិថិជនរបស់ឌីធី
12345
យល់ព្រម
កែតម្រូវ


សូមបញ្ចូលចំនួនប្រាក់ ដែលត្រូវបង់
$ 50.00
យល់ព្រម
កែតម្រូវទឹកប្រាក់


តើលោកអ្នកត្រូវការសន្លឹកវិក័យប័ត្រ
របាយការណ៍ដែរឬទេ?
ត្រូវការ
មិនត្រូវការ


សូមផ្ទៀងផ្ទាត់ការទូទាត់របស់លោកអ្នក:
ទូទាត់ទៅឱ្យ ឌីធីវីស្ទារ (ឌីធី)
លេខសំគាល់អតិថិជនឌីធី: 12345
ប្រាក់ដែលត្រូវបង់: $50.00
ត្រឹមត្រូវ
មិនត្រឹមត្រូវទេ




**២-តាមរយៈបណ្តាញអ៊ីនធើណិត របស់ធនាគារ ABA**

- ចូលទៅកាន់គេហទំព័ររបស់ធនាគារ ABA តាមរយៈ www.ababank.com ហើយចុចលើ iBank ឬក៏វាយបញ្ចូលដោយផ្ទាល់ពីកម្មវិធីរុករកអ៊ីនធើណិតរបស់លោកអ្នក https://secure.ababank.net។ មើលរូបភាពខាងក្រោម
- វាយបញ្ចូល ឈ្មោះអ្នកប្រើប្រាស់ ឬក៏លេខសំគាល់អតិថិជន(តាមរយៈលេខកូដ ឬតាមរយៈ អក្សរ) និងលេខសំងាត់ដើម្បីបញ្ជាចូលទៅក្នុងប្រព័ន្ធអ៊ីនធើណិតរបស់ធនាគារ ហើយចុច **ចូល**
- វាយបញ្ចូលលេខសំងាត់ចល័តដែលបានពីទូរស័ព្ទដៃ ឬក៏បានមកពីម៉ាស៊ីនគណនា (Crypto-Calculator)។ សូមមើលរបៀបប្រើប្រាស់នៃការទទួលបានលេខកូដសំងាតចល័តខាងក្រោម។
- សូមចុចលើពាក្យ **ការទូរទាត់** ហើយចុចយក **ធ្វើការទូរទាត់**
- សូមចុចលើពាក្យ Pay without Template
- សូមចុចលើពាក្យ Internet providers ហើយចុចលើពាក្យ DTV STAR
- បញ្ចូលព័ត៌ពីអ្នកធ្វើការទូរទាត់ ដូចជា៖ ចំនួនទឹកប្រាក់ដែលត្រូវបង់ និងរូបិយវត្ថុ ហើយនិងលេខសំគាល់អតិថិជនរបស់ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធើណិតឌីជី ហើយចុចលើពាក្យ Execute
- ចុចលើពាក្យ OK ដើម្បីបញ្ជាក់ការទូរទាត់
- វាយបញ្ចូលលេខកូដសំងាត់ចល័តដែលបានមកពីទូរស័ព្ទដៃ ឬក៏បានមកពីម៉ាស៊ីនគណនា ហើយចុច **ពាក្យទទួលយកការទូរទាត់**
- រង់ចាំឲ្យវាដំណើរការចប់រួចរាល់ ហើយវានឹងបង្ហាញផ្ទាំងដែលដំណើរការរួច។

  - ការបង្ហាញពីការអនុវត្តនៃការទូរទាត់វិក័យប័ត្ររបស់ឌីជីនៅក្នុងប្រព័ន្ធអ៊ីនធើណិតរបស់ធនាគារ ABA៖
    - ✓ ចូលទៅកាន់គេហទំព័ររបស់ធនាគារ ABA ហើយចុចលើពាក្យ iBank


ABA, Advanced Bank Of Cambodia - Mozilla Firefox
File Edit View History Bookmarks Tools Help
ABA, Advanced Bank Of Cambodia
New Tab
http://www.ababank.net/
Google
ABA BANK
Retail
Business
eService
iBank
About us
Contact us
News
Search...
ok
kh
Let's Pay!
With ABA Visa & MasterCard!
more
Let's Ride!
With ABA Moto Loans
more
Let's Save!
New Rates!
more
Let's Win!
With ABA Fixed Deposit
more

- ✓ បញ្ជាចូលទៅកាន់ប្រព័ន្ធអ៊ីនធើណិត iBank របស់ធនាគារ ABA




- ✓ បញ្ចូលលេខសំងាត់ចល័ត។ [សូមមើលពីរបៀបទទួលបានលេខសំងាត់ចល័ត]។
- ✓ បន្ទាប់ពីចូលក្នុងប្រព័ន្ធបានហើយ ចុចយក **ការទូរទាត់** ហើយចុច **ធ្វើការទូរទាត់**



- ✓ ចុចលើពាក្យ Pay without Template




- ✓ ចុចលើពាក្យ Internet providers ហើយចុចលើ DTV STAR



✓ វាយបញ្ចូលទិន្នន័យរបស់អតិថិជនឌីជី ហើយចុច Execute




✓ ចុច Ok ដើម្បីបន្តធ្វើការទូរទាត់




✓ បញ្ចូលលេខកូដសំងាត់ចល័ត។ សូមមើលពីរបៀបទទួលបានលេខកូដសំងាត់នៅខាងក្រោមនេះ។

✓ បន្ទាប់ពីធ្វើប្រតិបត្តិការរួចរាល់ហើយវានឹងបង្ហាញផ្ទាំងលទ្ធផល។


ABA BANK iBank

Accounts · Cards · Payments · Transfers · Purchases · Messages · Service · Exit · Print · Help

**Performed Payment Details**

Payment is successfully performed

*Approval Code 279670*

| | |
|---|---|
| Payer Account | 100000013576 \| USD \| |
| Amount | 50.00 $ |
| Date, time | 08/06/2011 12:16 |
| Comment | Payment for Jun 2011 |

APPROVED

Performed Payments List

## ✚ របៀបស្វែងរកព័ត៌មានអតិថិជនរបស់ក្រុមហ៊ុនអ៊ីនធើណិតឌីជីៈ

នៅក្នុងវិក័យប័ត្របង់ប្រាក់របស់ឌីជីរួមមានព័ត៌មានដូចជា លេខសំគាល់អតិថិជន(Customer ID or Agreement Number) ចំនួនទឹកប្រាក់ដែលត្រូវបង់ និងព័ត៌មានផ្សេងៗទៀត។ ក្រុមហ៊ុនអ៊ីនធើណិតឌីជីនឹងផ្ញើសារអេឡិចត្រូនិចពីវិក័យប័ត្រប្រើប្រាស់របស់អតិថិជនឌីជីតាមរយៈសារអេឡិចត្រូនិចជារៀងរាល់ចុងខែ។


Digi

**Digi Invoice**

**DTV STAR Co., Ltd.**

| | | | |
|---|---|---|---|
| Address: | #368, St 163, Olympic Quarter Chamkarmorn District, Phnom Penh, Cambodia | [redacted] | |
| Phone: | 023 227 766 | Address: | [redacted] |
| Fax: | 023 217 704 | Phone: | [redacted] |
| Email: | info@digi.com.kh | Customer ID: | 120058 |
| URL: | http://www.digi.com.kh | Invoice No.: | 34582 |
| VAT No.: | 100145957 | Issue Date: | 1st April 2011 |
| | | VAT No.: | |

| No. | Description | Price |
|---|---|---|
| 1 | Account Login : cheal1@digi | USD |
| | Subscription Name : Digi Home L-1Mbps 5000MB, 12 (Normal) | 10.91 |
| | Sub total for April 2011 | 10.91 |
| | VAT Charge ( 10 %) | 1.09 |
| | Invoice amount ( Include VAT ) | 12.00 |



## ✚ របៀបស្វែងយល់ពីលេខកូដសំងាត់ចល័តរបស់ប្រព័ន្ធអ៊ីនធើណិតធនាគារ ABA

លេខកូដសំងាត់ចល័ត គឺជាលេខកូដមួយដែលឲ្យអតិថិជនធនាគារអាចចូលទៅកាន់បណ្តាញអ៊ីនធើណិតរបស់ធនាគារ ឬក៏ប្រើប្រាស់សំរាប់ជាការយល់ព្រមរាល់ពេលធ្វើប្រតិបត្តិការទាក់ទងនិសាច់ប្រាក់របស់គណនីរបស់លោកអ្នក។

ការទទួលបានលេខសំងាត់ចល័ត មានពីរប្រភេទនៅពេលអតិថិជនចុះឈ្មោះប្រើប្រាស់ប្រព័ន្ធនេះជាមួយធនាគារ គឺះ

ក-<u>ការទទួលបានលេខនោះពីទូរស័ព្ទដៃរបស់អតិថិជនធនាគារ ABA ដោយផ្ទាល់</u>

លេខកូដសំងាត់ចល័តនេះ នឹងបញ្ជូនទៅកាន់ទូរស័ព្ទដៃរបស់អតិថិជនតាមរយៈសារ SMS រាល់ពេលដែលធ្វើការបញ្ជាចូលក្នុងប្រព័ន្ធ ឬក៏ក្នុងករណីយល់ព្រមទទួល ធ្វើប្រតិបត្តិការអ្វីមួយ។ ហើយលោកអ្នកត្រូវយកលេខកូដដែលបានទទួលក្នុងទូរស័ព្ទដៃមកវាយបញ្ចូលក្នុងប្រព័ន្ធអ៊ីនធើណិត iBank របស់ធនាគារ ABA បន្ទាប់មកចុចលើប៊ូតុង "**បន្ទាប់**"។




ខ-<u>ការទទួលបានលេខនោះពីម៉ាស៊ីនគណនា (Crypto Calculator)</u>

លេខកូដសំងាត់ចល័តនេះ គឺបានមកពីការគណនានៃម៉ាស៊ីនគណនាជាមួយនិងកាត CAP-Card។ ចំពោះអតិថិជនណាដែលបានជ្រើសរើសប្រើប្រព័ន្ធសុវត្ថិភាពនេះនឹងទទួលបានម៉ាស៊ីនគណនាមួយ (Crypto Calculator device) ជាមួយនិងកាតមួយ CAP-Card។

- ✓ រូបភាពនេះគឺនៅពេលដែលប្រព័ន្ធ iBank ទាមទាលេខសំងាត់ចល័តរាល់ពេលចូលក្នុងប្រព័ន្ធអ៊ីនធើណិតធនាគារ។ សូមមើលការណែនាំនៅលើរូបភាពនោះ។




✓ រូបភាពខាងក្រោមនេះគឺនៅពេលដែលប្រព័ន្ធ iBank ទាមទាលេខកូដសំងាត់ចល័តនៅពេលណាយល់ព្រមទទួលធ្វើប្រតិបត្តិការអ្វីមួយដែលទាក់ទងនឹងសាច់ប្រាក់ក្នុងគណនីរបស់អតិថិជន។ សូមមើលការណែនាំនៅលើរូបភាព។

